ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ៨១.០២៣.០៣៤.ប្រកាសព័ត៌មាន

ថ្ងៃសុក្រ ២កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០២៣

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់ការទូទាត់ឆ្លងដែនតាមរយៈឃ្យូអរកូត (QR Code) រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ (ដំណាក់កាលទី ១ ៖ កម្ពុជាស្កេនឃ្យូអរកូតនៅប្រទេសឡាវ "LAOQR")

នៅថ្ងៃសុក្រ២កើតខែស្រាពណ៍ ឆ្នាំថោះបញ្ចស័កព.ស២៥៦៧ត្រូវនឹងថ្ងៃទី១៨ខែសីហាឆ្នាំ២០២៣ លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាលធនាគារជាតិនៃកម្ពុជា និង ឯកឧត្តមបណ្ឌិត Bounleua Sinxayvoravong ទេសាភិបាលធនាគារកណ្តាលឡាវ បានអញ្ជើញជាអធិបតីក្នុងពិធីប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ការទូទាត់ឆ្លងដែនតាមរយៈឃ្យូអរកូត (QR Code) រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ (ដំណាក់កាលទី ១ ៖ កម្ពុជាស្កេនឃ្យូអរកូតនៅប្រទេសឡាវ) នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ។ គម្រោងនៃការតភ្ជាប់ការទូទាត់ឆ្លងដែន ចែកចេញជាពីរដំណាក់កាល គឺដំណាក់កាលទី១ "កម្ពុជាស្កេនឃ្យូអរកូតនៅប្រទេសឡាវ" ដែលបានអនុញ្ញាតឱ្យប្រជាជនកម្ពុជាដែលមានគណនីជាប្រាក់រៀលអាចប្រើប្រាស់កម្មវិធីធនាគារចល័ត ដើម្បីធ្វើការទូទាត់ប្រាក់តាមរយៈការស្កេនឃ្យូអរកូត (LAOQR) ទៅកាន់ពាណិជ្ជករ ឬ ហាងទំនិញនៅប្រទេសឡាវ និងដំណាក់កាលទី២ "ឡាវស្កេនឃ្យូអរកូតនៅប្រទេសកម្ពុជា" ដោយប្រជាជនឡាវ ដែលមានគណនីជាប្រាក់ឡាវគីប អាចទូទាត់ប្រាក់ដោយស្កេនខេអេចឃ្យូអរកូត (KHQR) ទៅកាន់ពាណិជ្ជករ ឬ ហាងទំនិញក្នុងប្រទេសកម្ពុជា។

ពិធីនេះ ត្រូវបានរៀបចំឡើងក្រោមកិច្ចសហការដ៏រឹងមាំ រវាងធនាគារកណ្តាលនៃប្រទេសទាំងពីរ បន្ទាប់ពីបានចុះអនុស្សរណៈយោគយល់ ស្តីពី "កិច្ចសហប្រតិបត្តិការផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់សងប្រាក់" រវាងធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលឡាវ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ ជាពិសេសការតភ្ជាប់ការទូទាត់ឆ្លងដែនរវាងប្រទេសទាំងពីរ ដែលប្រកបដោយសុវត្ថិភាព ងាយស្រួល ឆាប់រហ័ស និងតម្លៃសមរម្យ។

ថ្លែងក្នុងពិធីនោះផងដែរ លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានមានប្រសាសន៍ថា "កិច្ចសហការនេះ ក៏ដើរទន្ទឹមនឹងគោលបំណងនៃសហគមន៍អាស៊ាន ក្នុងការលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិក្នុងទីផ្សារ និងបានរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញបរិយាប័ន្នហិរញ្ញវត្ថុ។ ការណ៍នេះ ក៏រួមចំណែកពង្រឹងទំនាក់ទំនងសេដ្ឋកិច្ចកាន់តែជិតស្និទ្ធរវាងកម្ពុជា និងឡាវ ដែលនឹងគាំទ្រដល់ការស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិកូវីដ-១៩ និងអាចឱ្យប្រទេសទាំងពីរ

ឈានដល់កិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុមួយកម្រិតទៀត ក្នុងការប្រើប្រាស់បច្ចេកវិទ្យាដើម្បីជាប្រយោជន៍ដល់ប្រជាជនក្នុងប្រទេសទាំងពីរ"។

ឯកឧត្តមបណ្ឌិត Bounleua Sinxayvoravong ទេសាភិបាល ធនាគារកណ្តាលឡាវ ក៏បានលើកឡើងផងដែរថា "ធនាគារកណ្តាលឡាវ មានសេចក្តីសោមនស្សរីករាយដែលបានសហការជាមួយធនាគារជាតិនៃកម្ពុជា ហើយកម្ពុជា ជាប្រទេសដំបូងដែលបានតភ្ជាប់និងអភិវឌ្ឍការទូទាត់ឆ្លងដែនតាមរយៈឃ្យូអរកូត (QR Code) ជាមួយប្រទេសឡាវ បានជោគជ័យក្នុងដំណាក់កាលទី១ នេះ។ សម្រាប់ជំហានបន្ទាប់ ធនាគារកណ្តាលទាំងពីរនឹងបន្តអភិវឌ្ឍគម្រោងនេះសម្រាប់ដំណាក់កាលទី២។ ការណ៍នេះ បានបង្ហាញអំពីភាពជាដៃគូកាន់តែជិតស្និទ្ធរវាងប្រទេសទាំងពីរ លើការអភិវឌ្ឍផលិតផល និងសេវាប្រកបដោយនវានុវត្តន៍ ស្របតាមនិន្នាការសេដ្ឋកិច្ចក្នុងតំបន់និងសកលៈ ។


**ទំនាក់ទំនង ៖**

ផ្នែកទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា

ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៨០ ១៩៦

អ៊ីម៉ែល ៖ nbccommunication@nbc.gov.kh


**បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា៖**

www.nbc.gov.kh, www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA